ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខៈ ០៣៧/២៣ អអរ

## សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី «ភាពជោគជ័យរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង»

រសៀលថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ស៊ុន សុវណ្ណារិទ្ធិ អភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង**
- **មន្ទីរជំនាញជុំវិញខេត្តកំពង់ឆ្នាំង**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

### I. សេចក្តីផ្តើម

ខេត្តកំពង់ឆ្នាំង បែងចែកចេញជា ៨ ក្រុង-ស្រុក, ៧១ឃុំ-សង្កាត់ និង៥៦៩ភូមិ ដែលមានប្រជាជនសរុប ចំនួន ១៤០ ១៤៨គ្រួសារ ស្មើនឹងចំនួន ៥៧១ ០៦២នាក់ ក្នុងនោះ ប្រជាពលរដ្ឋប្រកបរបរកសិកម្មជាចម្បងចំនួន ៧២,២% សិប្បកម្មជាចម្បងចំនួន០,៦% និងសេវាកម្ម កម្មករពេងចក្រសហគ្រាសជាចម្បង ចំនួន២៧,២%។ ជាក់ស្តែង ក្នុងឆ្នាំ២០២១ ទំហំសេដ្ឋកិច្ចរបស់ខេត្តមានចំនួន ៣ ៧៤១ ៦៦១ លានរៀល ស្មើនឹង ៣% នៃសេដ្ឋកិច្ចជាតិ ដោយមានការចូលរួមពីវិស័យកសិកម្ម ៥៦,៧% វិស័យឧស្សាហកម្ម២៥,៧% និងវិស័យសេវាកម្មមាន ចំនួន១៧,៦% ហើយផលិតផលក្នុងស្រុកសរុប សម្រាប់មនុស្សម្នាក់ចំនួន ១ ៥៦៣,៧ដុល្លារអាមេរិក។

## II. សមិទ្ធផលសំខាន់ៗ

រដ្ឋបាលខេត្ត សម្រេចបាននូវសមិទ្ធផលសំខាន់ៗ រួមមាន៖

- **វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ខេត្តបាននិងកំពុងអនុវត្តគោលនយោបាយគាំពារសង្គម របស់រាជរដ្ឋាភិបាល ដោយបានឧបត្ថម្ភជូនគ្រួសារក្រីក្រ ២៧ ៧៨២ គ្រួសារ ចំណាយថវិកាចំនួន ១៤៥ ៤៥៤ ៩៧៦ ០០០ រៀល។ បានបើកថវិកាជូនស្ត្រីមានផ្ទៃពោះចំនួន ៥ ០៧៦នាក់ និងកុមារអាយុក្រោម២ឆ្នាំចំនួន ១ ៧៤៥ អស់ថវិកាចំនួន ២ ៧១៣ ៨០០ ០០០រៀល និងបានផ្តល់ប្រាក់បន្ថែម របស់រាជរដ្ឋាភិបាលជូនកម្មករ និយោជិកជាស្ត្រី នៅពេលសម្រាលកូនមានចំនួន ២ ៧៦២នាក់ ទឹកប្រាក់សរុប ១ ១១៣ ៦០០ ០០០ រៀល ព្រមទាំងបានបើកផ្តល់សាច់ប្រាក់ដល់គ្រួសាររងាយរងហានិភ័យ ទឹកជំនន់ និងសម្ពាធអតិផរណា ចំនួន ២១ ៧៤៤ នាក់។ បន្ថែមពីនេះ ខេត្តបានអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ដោយបានផ្តល់ប័ណ្ណកម្មសិទ្ធិចំនួន ១៧៤ គ្រួសារ និងកម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រស៊ីវិល បានផ្តល់ប័ណ្ណកម្មសិទ្ធិចំនួន ៧៣២ គ្រួសារផងដែរ។
- **វិស័យកសិកម្ម៖** ខេត្តបានដាក់ចេញនូវគោលដៅសំខាន់សម្រាប់វិស័យកសិកម្មគឺ ធានាបាននូវសន្តិសុខស្បៀង បង្កើនប្រាក់ចំណូល បង្កើតឱ្យមានការងារធ្វើ និងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភ សម្រាប់ប្រជាជនតាមរយៈការបង្កើនផលិតភាពកសិកម្ម ចេះប្រើប្រាស់ពូជដី ធ្វើស្រែ បង្កើនរដូវ ការធ្វើពិពិធភាវូបនីយកម្ម និងការធ្វើពាណិជ្ជកម្មវិស័យកសិកម្ម ដោយគិតគូរដល់កិច្ចការពារបរិស្ថានប្រកបដោយចីរភាព និងសន្តិសុខស្បៀង។ ជាលទ្ធផល ក្នុងឆ្នាំ២០២២ ចំពោះផលស្រូវសរុបដែលទទួលបានគឺ ៧០៧ ០៨៣តោន មានការកើនឡើងបើធៀបនឹងឆ្នាំ ២០១៨ មានត្រឹម ៥៦២ ០៧៧តោន។ ក្រៅពីនេះ ចំពោះដំណាំរួមផ្សំ និងកសិឧស្សាហកម្ម, ផលិតកម្មសត្វ និងជលផល ក៏ទទួលបានទិន្នផលកើនឡើងជាប្រចាំផងដែរ។
- **ការងារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍៖** ខេត្តបានអភិវឌ្ឍបណ្តាញផ្លូវគមនាគមន៍ ដោយធ្វើការសាងសង់ ជួសជុលថែទាំ និងការកែលម្អលើកកម្ពស់គុណភាពបណ្តាញថ្នល់ផ្លូវកាន់តែប្រសើរឡើង ក្នុងការជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ ដោយបានកសាងផ្លូវគមនាគមន៍ក្នុងទីប្រជុំជន និងផ្លូវជនបទជា ជំហានៗ ពីផ្លូវលំដីស ផ្លូវក្រាលក្រួសក្រហម មកជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុងដែលបានអនុវត្តគម្រោងដោយ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរអភិវឌ្ឍន៍ជនបទ គម្រោងរដ្ឋបាលខេត្ត គម្រោងរដ្ឋបាលក្រុង ស្រុក គម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងរបស់ក្រសួងស្ថាប័ន ពាក់ព័ន្ធផ្សេងៗទៀត។

- **ការងារអភិវឌ្ឍន៍ជនបទ៖** ខេត្តបានខិតខំជំរុញការអភិវឌ្ឍការងារអភិវឌ្ឍន៍ជនបទនេះ ដោយផ្តោតសំខាន់ទៅលើ វិស័យទឹកស្អាត បរិស្ថាន និងអនាម័យជនបទ ក្នុងនោះសម្រេចបានសមិទ្ធផលជាច្រើនដូចជា ការថែទាំផ្លូវជាប្រចាំថែទាំផ្លូវខួប ការសាងសង់អណ្តូងស្នប់ អណ្តូងលូ បង្គន់អនាម័យតាមផ្ទះ បង្គន់សាធារណៈ ពាងត្រងទឹកភ្លៀងតាមផ្ទះ អាងចម្រោះទឹកសាធារណៈ និងសហការជាមួយអង្គការស្បៀងអាហារពិភពលោកអនុវត្តគម្រោងស្បៀង ពលកម្ម និងសាច់ប្រាក់ពលកម្មផងដែរ ជាពិសេស ខេត្តសម្រេចបាននូវគម្រោង ODF និងត្រូវបានប្រកាសទទួលស្គាល់ថា ជាខេត្តដែលបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល។
- **វិស័យព័ត៌មាន៖** ព័ត៌មានបានដើរតួនាទីជាស្ពានភ្ជាប់រវាងរាជរដ្ឋាភិបាល ជាមួយនឹងប្រជាពលរដ្ឋផ្ទាល់ ក្នុងការផ្តល់ឱ្យប្រជាជន ទទួលបានព័ត៌មានពាក់ព័ន្ធនឹងគោលនយោបាយលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល ដើម្បីឱ្យប្រជាជនបានយល់ដឹងច្បាស់ និងបានចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គមជាតិ។ បច្ចុប្បន្ននេះ ខេត្តមានស្ថានីយ៍វិទ្យុFM របស់រដ្ឋចំនួន ០១ស្ថានីយស្ថានីយវិទ្យុFM របស់ឯកជនចំនួន ១៦ស្ថានីយ៍ ស្ថានីយ៍វិទ្យុបណ្តាញមានចំនួន ០២ស្ថានីយ និងស្ថានីយទូរទស្សន៍ខ្សែកាបមានចំនួន ០៩ស្ថានីយ។

## III. សម្គាល់

រាជរដ្ឋាភិបាល តែងតែគិតគូពីប្រជាពលរដ្ឋជាចម្បង ទាំងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជួយដល់គ្រួសារក្រីក្រ និងងាយរងគ្រោះដោយជំងឺកូវីដ-១៩ ស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ ២ឆ្នាំ និងគ្រួសារងាយរងហានិភ័យដោយប្រការផ្សេងៗជាដើម។ ជាមួយគ្នានោះ រដ្ឋបាលខេត្តកំពង់ឆ្នាំង បាន និងកំពុងអនុវត្តការងារកាត់ឆ្វៀលផ្ទៃដីជូនប្រជាពលរដ្ឋក្នុងតំបន់២ និងតំបន់៣ បាន២លើករួចមកហើយ ក្នុងនោះ បានសម្រេចកាត់ឆ្វៀលដីទំហំ ២៥៣ ហិកតា ចេញពីតំបន់៣ និងផ្តល់ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៦ ៨៨ គ្រួសារ និងកែសម្រួលផ្ទៃដីទំហំ ៣ ៣៩១ ហិកតា ចេញពីតំបន់៣ បញ្ចូលជាតំបន់២ ជូនប្រជាពលរដ្ឋចំនួន ១៦ ៨៨ គ្រួសារសម្រាប់ប្រើប្រាស់ និងអាស្រ័យផល និងលើកទី២ បានសម្រេចកាត់ឆ្វៀលដីទំហំ ៧៤១,១៧ ហិកតា ចេញពីតំបន់៣ ផ្តល់ជូនសម្រាប់ប្រជាពលរដ្ឋដែលផ្លាស់ទីមកពីផ្ទះនៅលើទឹកចំនួន ៤៤៣,៦៣ហិកតា សម្រាប់គម្រោងវារីវប្បកម្មចំនួន ២២២,៥៤ហិកតា និងសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ៧៥ហិកតា៕

ថ្ងៃព្រហស្បតិ៍ ៥កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣